សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសេរីភាព និងការតស៊ូមតិ
NGO Alliance for Freedom & Advocacy (NAFA)
No: 16A0, Street 318, Sangkat Toul Svay Prey I, Khan Chamkarmon
Phnom Penh, Cambodia, Tel: (855) 12 525 552 Email: nafa@online.com.kh

NAFA is an Alliance of

Bright Society (BS)
Khmer Peace Organization (KPO)
Phnom Neangkangrey Association (PNA)
Association Alliance for Rural Restoration (AARR)
Support Association Farmer (SAF)
Chris Development of Kampuchea (CDK)
Women Association for Community Development (WACD)
Khmer Farmer Development (KFD)
Rural Community Environment Development Organization (RCEDO)
Friend' Pioneer Association (FAP)
Human Resource and Nature Development (HRND)
Health car Aids Prevention Organization (HAPO)
Old Age of Miserable People Health Organization (HOM)
Khmer Association for Development of Countryside Cambodia (KAFDOC)
Community Economic Development (CED)
Cambodian Rights & Justice Protection Organization (CARIPO)
Hoped Children for Development Organization (HCDO)
Free Trade Union (FTU)
Cambodia Sociology Club (CSC)
Cambodia Independent Teacher Association (CITA)

# សង្គមរាស្ត្រនិយមរបស់ នរោត្តម សីហនុ
# ជាបុព្វហេតុ បង្កើតអោយមានរបបខ្មែរក្រហម

គណៈបក្សសង្គមរាស្ត្រនិយម ដែលដឹកនាំដោយ សម្តេច នរោត្តម សីហនុ កាលពីទសវត្សឆ្នាំ៦០ គឺជាបុព្វហេតុ តែមួយគាត់ដែលបង្កើតអោយមានរបបខ្មែរក្រហមសំលាប់រង្គាលនៅកម្ពុជា។ ថ្វីត្បិតតែ សង្គមរាស្ត្រនិយមនេះ បានផ្តល់សន្តិភាព និងកាអភិវឌ្ឍន៏មួយរយៈខ្លីនោកម្ពុជា ក៏ដោយ តែរបបនេះ កើតឡើងដោយអំពើរក្តៅក្រហាយ ដោយសារតែមេដឹកនាំ និងមន្ត្រីគណៈបក្សនេះបានប្រើអំណាចផ្តាច់ការ ការសំលាប់គំរាមអ្នកប្រជាធិបតេយ្យ និងប្រើកលល្បិចគ្រប់បែបយ៉ាង ដើម្បីទំលាក់កំហុសលើ គណៈបក្សប្រជាធិបរតយ្យ ក្នុងគោលបំណងធ្វើប្រជាភិថុរអោយប្រជារាស្ត្រយល់ប្រឡំ ហើយបោះឆ្នោតអោយខ្លួន។

ដោយមាន សម សារី ជាមេចារកម្ម និងបង្កភាវរកម្ម នរោត្តម សីហនុ បានបញ្ជាអោយមនុស្សរបស់ខ្លួនធ្វើបាបអ្នកប្រជាធិបតេយ្យ ដែលមិនគាំទ្រខ្លួន។ ដោយមានរាជវាំងនៅពីក្រោយខ្នង នរោត្ត សីហនុ បានបំបាត់ដាននូវត្តិសាស្ត្រ ដែលទទួបានឯករាជ្យពីបារាំងថា គឺជាគុណសម្បត្តិរបស់ខ្លួនតែមួយ ហើយបានជីករណ្តៅកប់ គុណសម្បត្តិរបស់ចលនាខ្មែរឥស្សរៈ ដែលទទួលស្គាល់ដោយសន្និសិទ្ធ ក្រុងហ្សឺណែវ។ ទង្វើដ៏ និងកលល្បិចនយោបាយដ៏ថោកទាបនេះ បានធ្វើអោយអ្នកជាតិនិយមខ្មែរ រួមជាមួយនិង អ្នកប្រជាធិបតេយ្យនិយម ទទួលរងនូវការឈឺចាប់ តែមិនមានឱកាស់បានបកស្រាយ អោយរាស្ត្របានស្តាប់ ដោយសាតែប្រព័ន្ធផ្សព្វផ្សាយទាំងមូល និងអំណាចត្រូវបានគ្រប់គ្រងដោយបុគ្គលតែម្នាក់នាពេលនោះ គឺ នរោត្តម សីហនុ ហើយបើអ្នកណាមួយ ឬក្រុមណាហានធ្វើការរិះគន់ ឬប្រឆាំង គឺត្រូវបានចាប់ យកទៅបាញ់សំលាប់ចោល ដោយចោទថា ក្បត់រាជបល័ង្គ។

ការប្រកាស់ហៅអោយ របជាជនចូលព្រៃម៉ាកគី ដែលនរោត្តម សីហនុ បោកបញ្ឆោតថាដើម្បីវាយពួកចព្រត្តិនិយមអាមេរិក គឺជាក្តាអុក ដែលគិតថា អាចនាំខ្លួនមកកាន់អំណាចវិញ បន្ទាប់ពីមនុស្សជំនិតរបស់ខ្លួន គឺលោក លន់ ណុល បានធ្វើរដ្ឋប្រហារទំលាក់ខ្លួនចេញពីអំណាច។ ចលនាព្រៃម៉ាកគីរបស់ នរោត្តម សីហនុ ដែលក្រោយមកបានក្លាយទៅជាចលនា ខ្មែរក្រហម គឺអាចផ្តួលរំលំរបបសាធារណៈរដ្ឋ

របស់លោក លន់ ណុល បានដូចបំណង។ នៅពេលដែលកម្ពុជា ប្រជាធិបតេយ្យបានកាន់អំណាច និងក្នុងគោលបំណងសងសឹកអ្នកប្រជាធិបតេយ្យ និងអ្នកសាធារណៈរដ្ឋដែលមិនគាំទ្រខ្លួនពីមុនមក នរោត្តម សីហនុ បានប្រើប្រាស់តួនាទីជាប្រមុខរដ្ឋបញ្ជាអោយសំលាប់អ្នកទាំងនោះ ដូចដែលខ្លួនបញ្ជាអោយសំលាប់អ្នកប្រជាធិបតេយ្យកាលនៅកាន់អំណាចក្នុងរបបសង្គមរាស្ត្រនិយម។ នរោត្តម សីហនុ បានចាត់ទុកប្រជាជនកម្ពុជាខ្លួនឯងទាំងមូលថាជា ស៊ីអេអា របស់អាមេរិក ហើយបានដាក់ទោសយ៉ាងធ្ងន់ដោយបង្អត់បាយ និងធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ។ សក្ខីភាពទាំងនេះបានបញ្ជាក់យ៉ាងច្បាស់តាមរយៈរូបភាពឯកសារជារូបថត និងជាភាពយន្ត ដែលបង្ហាញពីស្នាមញញឹមយ៉ាងពេញចិត្តរបស់ សម្តេច នរោត្តម សីហនុ និងអ្នកម្នាង មនីនាថ ក្នុងសំលៀកបំពាក់ខ្មៅ ក្រម៉ាក្រហម ពេលចុះមើលសួរសុខទុករបស់ប្រជាជនកម្ពុជា កំឡុងរបបខ្មែរក្រហម។

បើ នរោត្តម សីហនុ ពិតជាមិនមែនមេខ្មែរក្រហម ហើយជាស្តេចល្អមួយអង្គ តើស្តេចអង្គនេះល្ងីល្ងើពកថ្ងាស់ ឬយ៉ាងណា បានជាពេលចុះសួរសុខទុករាស្ត្រ មិនចេះមើលសាច់ មើលឈាម ប្រជារាស្ត្រថាតើ រាស្ត្រហូបឆ្អែត ឬមិនឆ្អែត? ឈឺ ឬជា? ព្រះរាជវាំងតាំងនៅទីក្រុងភ្នំពេញ ហើយជុំវិញវាំងគឺមានវត្តឧណ្ណាលោម និងវត្តបុទុម តើស្តេចអង្គនេះ ដែលចាត់ទុខ្លួនឯងជាអ្នកទ្រទ្រង់ព្រះពុទ្ធសាសនា ពិតជាល្ងើមិនដឹងថាវត្តគ្មានព្រះសង្ឃ និងទីក្រុងគ្មានមនុស្សឬ? ជារួមពាក្យថាក្បត់រាជបល័ង្គ និងក្បត់អង្គការមានន័យតែមួយ ដែលនរោត្តម សីហនុ និងបក្ខពួកប្រើដើម្បីសំលាប់ប្រជាជនកម្ពុជា ហើយជាក់ស្តែងជាងនេះទៅទៀត ប្រទេសចិនប្រជាមានិត ដែលជាមហាមិត្ត របស់ សម្តេចនរោត្តម សីហនុ គឺជាមេផ្តល់ជំនួយគាំទ្រ ព្រមទាំងជាអ្នកផ្តល់ឧបករណ៍ធ្វើទារុណកម្មមនុស្សនៅគុកទួលស្លែង និងមន្ទីសំលាប់មនុស្សឯទៀត តើការទំនាក់ទំនងបែបនេះ នរោត្តម សីហនុ អាចប្រកែកបានទេ? ការដែល នរោត្តម សីហនុ លាលែងពីដំណែងប្រមុខរដ្ឋ នៃរបបខ្មែរក្រហម គឺគ្រាន់តែជាលែស ដើម្បីលាងសំអាត ដៃដែលប្រឡាក់ឈាមតែប៉ុណ្ណោះ ការដែល នរោត្តម សីហនុ និយាយថា ខ្លួននិងស្រគ្រួសារក៏ជាប់គុកដែរក្នុងរបបខ្មែរក្រហម និងមានកូន មានចៅ ត្រូវខ្មែរក្រហមសំលាប់ដូចគ្នា គឺគ្រាន់តែជាពាក្យដោះសារ និងមានគោលបំណងរំដោះខ្លួនពីការទទួលខុស និងមិនព្រមទទួលយកកំហុសដែលខ្លួនបានប្រព្រឹត្តិតែប៉ុណ្ណោះ ព្រោះថាតើមាននណាដែលដឹងថា នរោត្តម សីហនុ មានកូនប៉ុន្មាននាក់? មានចៅប៉ុន្មាននាក់? មានប្រពន្ធដែលគេដឹងប៉ុន្មាននាក់? និងមានប្រពន្ធលួចលាក់ប៉ុន្មាននាក់?

ជារួម ខ្មែរក្រហម គឺ នរោត្តម សីហនុ ជាអ្នកបង្កើត ការស្លាប់របស់ខ្មែរក្នុងរបបនេះគឺ នរោត្តម សីហនុ ជាអ្នកទទួលខុសត្រូវ ដូច្នោះអង្គជំនុំជំរះដែលបង្កើតឡើងនេះ អាចកោះហៅ តែនរោត្តម សីហនុ ម្នាក់មកសួរចំឡើយ គឺអាចនាំយកបក្ខពួកឯទៀតមកដាក់គុកបានហើយ ដើម្បីរកយុត្តិធិ អោយប្រជាជនដែលស្លាប់បាត់បង់ជីវិត។ ដោយសារខ្លាចនិងស្រមោលអតិតកាលរបស់ខ្លួននេះហើយ ទើបបានជាសម្តេច នរោត្ត សីហនុ ម្តងគាំទ្រអោយមានអង្គជំនុំជំរះ ម្តងមិនគាំទ្រ និងតែងតែទទូចអោយគេធ្វើការបូជាឆ្អឹងអ្នកស្លាប់ក្នុងរបបខ្មែរក្រហមចោល ដើម្បីបំបាត់ភស្តុតាង។

ខ្ញុំសូមបញ្ជាក់ថា ទង្វើរបស់ សម្តេច នរោត្តម សីហនុ និងគណៈបក្សសង្គមរាស្ត្រនិយម បានធ្វើកាលពីទសវត្សឆ្នាំ៦០ ទៅលើអ្នកប្រជាធិបតេយ្យ គឺមិនខុសពី លោក ហុន សែន និងគណៈបក្សប្រជាជនកម្ពុជា បានធ្វើមកលើប្រជាជន និងអ្នកប្រជាធិបតេយ្យនាពេលនេះដែរ។ ពោលគឺ នរោត្តម សីហនុ និងសង្គមរាស្ត្រនិយម ហ៊ុន សែន និងគណៈបក្សប្រជាជនកម្ពុជា គឺជាខ្មែរក្រហម និងកុំមុយនីស តែមួយ ហេតុផលនេះបានបញ្ជាក់តាមរយៈ របៀបគំរាមធ្វើបាប និងសំលាប់មនុស្សដូចគ្នា ប្រើអំណាចផ្តាច់ការដូចគ្នា ពូកែប្រើនយោបាយប្រជាភិថុរដូចគ្នា និងជាពិសេសក្រឡិចក្រឡុច គ្មានសច្ចៈភាព និងគ្មានសីលធមិ ជាអ្នកដឹកនាំដូចគ្នា។

សហរដ្ឋអាមេរិក ថ្ងៃទី០២ សីហា ឆ្នាំ២០០៦

ហត្ថលេខា



**សួន រដ្ឋា**

**President of NGO Alliance for Freedom & Advocacy (NAFA)**
**Tel: 1 703 967 9717 Email: sournratha@hotmail.com**